ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខៈ ៣៥០ គ.ជ.ប

# គោលការណ៍

## សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សាអំពីកម្មវិធីនយោបាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមកំណត់នូវគោលការណ៍សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សាអំពីកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ដូចខាងក្រោមៈ

## ១. កិច្ចសហការជាមួយ គ.ជ.ប

### ១.១ ការពិគ្រោះយោបល់

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ មុននឹងចាប់ផ្តើមធ្វើកម្មវិធីនេះ លើបញ្ហាមួយចំនួនដូចជាៈ

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំធ្វើ
- ប្រធានបទ ឬសំណួរដែលត្រូវដាក់ជូនគណបក្សនយោបាយ
- ការសម្របសម្រួលទីតាំងប្រជុំ សន្តិសុខ និងសុវត្ថិភាព។

### ១.២ ការទទួលខុសត្រូវ

សាមីសមាគម អង្គការ ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលរៀបចំកម្មវិធី ត្រូវទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយកម្មវិធីនយោបាយនេះ និងទទួលបន្ទុករាល់ការចំណាយទាំងអស់។

## ២. កិច្ចដំណើរការកម្មវិធី

កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤។ កម្មវិធីនេះអាចធ្វើនៅទីសាធារណៈ ឬកន្លែងឯកជនថ្នាក់រាជធានី ខេត្ត ឬនៅថ្នាក់ជាតិ និងតាមស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់។ ដើម្បីឱ្យដំណើរការកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សានេះ ប្រព្រឹត្តទៅមានភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

### ២.១ ការត្រៀមរៀបចំមុនកម្មវិធីចាប់ផ្តើមដំណើរការ

- ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរ អញ្ជើញតំណាងគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ជាផ្លូវការ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុងកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា
- យោងតាមកម្រិតនៃការរៀបចំនៅថ្នាក់រាជធានី ខេត្ត ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៅតាមរាជធានី ខេត្ត ឬគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីនៅតាមរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមរាជធានី ខេត្ត ឬនៅទូទាំងប្រទេសបានចូលរួម

- ត្រូវផ្តល់ប្រធានបទ និងសំណួរដែលត្រូវចោទសួរក្នុងកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា ជូនគណបក្សនយោបាយយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី
- ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញនោះហើយ តែពុំបានចាត់តំណាងរបស់ខ្លួនឱ្យទៅចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថា គណបក្សនយោបាយនោះ បោះបង់ចោលពេលវេលារបស់ខ្លួន ហើយកម្មវិធីនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់។

### ២.២ ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

- កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អាចធ្វើនៅទីសាធារណៈ ឬកន្លែងឯកជននៅតាមរាជធានី ខេត្ត
- កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អាចធ្វើនៅស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់តែម្តង
- កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អាចអញ្ជើញប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទជាសំណួរបាន ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន។

### ២.៣ អ្នកសម្របសម្រួលកម្មវិធី

អ្នកសម្របសម្រួលកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាពក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព។

### ២.៤ ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សាតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម

កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សាអំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម ត្រូវបានអនុវត្តដូចខាងក្រោម៖

- កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា ដែលធ្វើនៅតាមរាជធានី ខេត្តណាមួយ អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលមានស្ថានីយនៅក្នុងរាជធានី ខេត្តនោះ និងតាមបណ្តាញសង្គម
- កម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អាចផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍នៅថ្នាក់ជាតិ និងបណ្តាញសង្គមបាន លុះត្រាតែអនុវត្តតាមចំណុច ២.១ ខាងលើនេះ។

## ៣. គោលការណ៍អនុវត្ត

- អ្នកគ្រប់គ្រងកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ត្រូវតែអព្យាក្រឹត និងមិនលម្អៀង
- ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬកិច្ចពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងគោលការណ៍នេះ៕

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ